**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**
លេខ : ២៣៧៤/២០ អ គ រ

ថ្ងៃ ច័ន្ទ ៣រោច ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០២០

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុវត្តពិធីសារទី១ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន

យោងតាមលិខិតលេខ ៨១១៣ សហវ.អគប ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជន និងភាគីពាក់ព័ន្ធទាំងអស់ឱ្យបានជ្រាបថា ពិធីសារទី១ ធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន(ATIGA) សម្រាប់គាំទ្រដល់ការអនុវត្តនូវស្វ័យបញ្ជាក់ដើមកំណើតទូទាំងអាស៊ាន (ASEAN-Wide Self-Certification-AWSC) បានចូលជាធរមាននៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២០ នេះតទៅ។ ទន្ទឹមនេះ មានវិធានពាក់ព័ន្ធផ្សេងៗចំនួន ៣ នៅក្នុងវិសោធនកម្មនីតិវិធីប្រតិបត្តិនៃការបញ្ជាក់ដើមកំណើត (Amended Operational Certification Procedure-OCP) និងវិញ្ញាបនបត្រដើមកំណើតទម្រង់ D (ATIGA CO Form D)រួមទាំងកំណត់សម្គាល់នៅទំព័រខាងខ្នង (Overleaf Notes) នៃ CO Form ដែលត្រូវបានកែសម្រួល ក៏ត្រូវបានចាប់ផ្តើមអនុវត្តនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២០ នេះផងដែរ។ វិធានពាក់ព័ន្ធទាំង ៣ មានដូចខាងក្រោម៖

១ វិធានទី៧៖ អនុញ្ញាតឱ្យប្រើប្រាស់ហត្ថលេខា និងត្រាក្នុងទម្រង់អេឡិចត្រូនិច (Electronically Applied Signatures and Seals)។

២ វិធានទី១១៖ ដាក់បញ្ចូលនូវកាលបរិច្ឆេទនៃការចេញ និងលេខយោងនៃវិញ្ញាបនបត្រដើមកំណើតច្បាប់ដើមសំដៅកំណត់សុពលភាពនៃវិញ្ញាបនបត្រដើមកំណើតបន្ត (Back-to-back CO FORM D) និង

៣ វិធានទី២៥៖ បន្តបង្ហាញតម្លៃFOB លើCO Form D ដែលចេញមកកាន់ប្រទេសកម្ពុជា ក្នុងករណីដែលប្រើប្រាស់វិធានសមាសភាគតម្លៃក្នុងតំបន់ (RVC)។

ទោះជាយ៉ាងណាក៏ដោយ ក្នុងដំណាក់កាលដំបូងនេះ ប្រសិនបើធុរជនពុំទាន់អាចផ្តល់ ATIGA CO Form D ទម្រង់ថ្មីបាន អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នឹងបន្តទទួលយក ATIGA CO Form D ទម្រង់ចាស់ រហូតដល់ **ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០**។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងធុរជនពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តប្រកបដោយប្រសិទ្ធភាព។

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**


ព័ត៌មានលម្អិតសូមទំនាក់ទំនង៖

- ការិយាល័យដើមកំណើតទំនិញ
  - លេខទូរស័ព្ទ៖ ០១២ ៥០៥ ០៧៨/ ០៩២ ៨៦៦ ៦៧៩
  - អ៊ីម៉ែល៖ roo@customs.gov.kh
- ការិយាល័យពាណិជ្ជកម្មសេរី
  - លេខទូរស័ព្ទ ០១២ ៨១៤ ៩៥០/០១៧ ៩១៩ ៩៤៥
  - អ៊ីម៉ែល៖ international-affairs@customs.gov.kh